លេខ : ................ ភ្នំពេញ ,ថ្ងៃទី ខែ ឆ្នាំ២០០៩

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**ជំរាបមក**

**លោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត**

**កម្មវត្ថុ** : ការណែនាំ ស្តីពីការចុះបញ្ជីដីរដ្ឋ ដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង និងការចុះបញ្ជីសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិលើការជួលរយៈពេលវែង ។

**យោង** : - អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ

- អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការដាក់បញ្ចាំ-ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនលោកស្រី អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា : ដើម្បីចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលរយៈពេលវែង ជូនម្ចាស់សិទ្ធិតាមការស្នើសុំបាន លុះត្រាតែដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែងនោះ ត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋជាមុនសិន ។ ការចុះបញ្ជីដីរដ្ឋអាចអនុវត្តតាមអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យលេខ ៤៨ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ចំពោះការអនុវត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចខាងក្រោម សំរាប់គ្រប់ក្បាលដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង :

១. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ត្រូវស្នើឱ្យបុគ្គលដែលទទួលបានសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរកាន់កាប់ដីរដ្ឋ បោះបង្គោលរឹងមាំតាមព្រំដីដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ។ មន្ទីរត្រូវរៀបចំប្រកាសស្តីពីការចុះដាំបង្គោលព្រំដី ចុះហត្ថលេខាដោយអភិបាលស្រុក ខណ្ឌ ឬក្រុង ដែលជាសមត្ថកិច្ចដែនដី(គំរូភ្ជាប់) ដើម្បីជូនសាធារណជនជ្រាបមុន និងចូលរួមតាមកាលបរិច្ឆេទកំណត់ ។

២. មន្ទីរត្រូវចាត់មន្ត្រីចុះពិនិត្យព្រំដី ធ្វើការវាស់វែង រួចគូរប្លង់ដីរដ្ឋ និងកសាងកំណត់ហេតុអង្កេតដី ឬទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងឯកសារផ្សេងទៀតដែលចាំបាច់ ។ ក្រសួងប្រគល់សិទ្ធិវាស់វែងដីរដ្ឋ ជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដោយត្រូវប្រើប្រាស់ឧបករណ៍វាស់វែងតាមក្បួនខ្នាតបច្ចេកទេសតម្រូវ ។ មន្ទីរអាចប្រើឧបករណ៍ GPS កាន់ដៃដែលមានកំរិតលំអៀងក្រោម០៨ម៉ែត្រ ដើម្បីធ្វើការវាស់វែងជ្រុងដីរដ្ឋដែលមានព្រំជាប់នឹងដីរដ្ឋ ។ ចំពោះជ្រុងដែលមានការពាក់ព័ន្ធនឹងដីឯកជន តម្រូវឱ្យធ្វើការវាស់វែងដោយឧបករណ៍ដែលមានកំរិតជាក់លាក់ខ្ពស់ ដើម្បីចៀសផុតពីភាពជាន់លើចំណែកដីរបស់បុគ្គលឯកជន ដែលអាចនាំដល់វិវាទ ។ ក្នុងករណីពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការ

វាស់វែង មន្ទីរអាចលើកសំណើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សុំមន្ត្រីជំនាញទៅបំពេញភារកិច្ចវាស់វែង និងកសាងប្លង់ដីរដ្ឋជូនបាន ។

៣. មន្ទីរត្រូវបញ្ជូនប្លង់ដីរដ្ឋដែលបានកសាងរួច ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី-ខេត្ត ដើម្បីធ្វើការប្រជុំពិភាក្សា ធ្វើចំណាត់ថ្នាក់ដី ថាជាដីឯកជនរបស់រដ្ឋ និងធ្វើការវាយតម្លៃផលប៉ះពាល់ផ្សេងៗ ។ ក្នុងករណីដីរដ្ឋ ជាប្រភេទទ្រព្យសាធារណៈ មន្ទីរត្រូវលើកសំណើទៅអភិបាលខេត្ត ជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ដើម្បីរៀបចំអនុក្រឹត្យសុំធ្វើ អនុបយោគទីតាំងឱ្យទៅជាទ្រព្យឯកជននៃរដ្ឋ ។

៤. មន្ទីរត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់ដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ក្នុងរយៈពេល៣០(សាមសិប) ថ្ងៃ នៅសាលាឃុំ-សង្កាត់ និងសាលាស្រុក ខណ្ឌ ក្រុង ដើម្បីផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធធ្វើការជំទាស់ ឬតវ៉ា ។

៥. ផុតរយៈពេលបិទផ្សាយជាសាធារណៈ មន្ទីរត្រូវធ្វើរបាយការណ៍បូកសរុប និងស្នើសុំការសំរេចលើឯកសារ (ប្លង់សុរិយោដី កំណត់ហេតុ អង្កេតដី ឬទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី) ពីអភិបាលរាជធានី-ខេត្ត រួចចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានសេដ្ឋកិច្ច ឬជួល រយៈពេលវែងនោះ (ចំណែកដីដែលមិនពាក់ព័ន្ធនឹងដីសាធារណៈ ឬ/និងដីប្រជាពលរដ្ឋកំពុងកាន់កាប់) ចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ ។

៦. នៅត្រង់ខ្ទង់សេចក្តីផ្សេងៗនៃសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដីធ្លី និងនៅលើប័ណ្ណ ត្រូវសរសេរបញ្ជាក់ថា " ដីឯកជនរបស់រដ្ឋ តាមកំណត់ហេតុចំណាត់ថ្នាក់ដី/អនុក្រឹត្យអនុបយោគលេខ ..... ចុះថ្ងៃ ..... " ។

៧. ក្រោយពីក្បាលដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ត្រូវបានចុះបញ្ជីរួច មន្ទីរត្រូវធ្វើការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលរយៈពេលវែង ចូលក្នុងសៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសៀវភៅចុះបញ្ជីសិទ្ធិជួលរយៈពេលវែង ដែលបានបង្កើតឡើងសំរាប់ចុះបញ្ជីសិទ្ធិទាំងនោះដាច់ដោយឡែក តាមរូបមន្តដូចខាងក្រោម :

- នៅលើសៀវភៅចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬសៀវភៅចុះបញ្ជីសិទ្ធិជួលរយៈពេលវែង និងនៅលើវិញ្ញាបនបត្រសំគាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ឬជួលរយៈពេលវែង ត្រង់ខ្ទង់លេខាចារឹកដោយសង្ខេប ត្រូវសរសេរថា "**ទទួលបានសិទ្ធិសម្បទានដីសេដ្ឋកិច្ចពីរដ្ឋ រយៈពេល ... (...) ឆ្នាំ ចាប់ពី ..... ដល់ ..... តាមកិច្ចសន្យាចុះថ្ងៃ .....**" ឬ "**ជួលពី .....រយៈពេល ... (...) ឆ្នាំ ចាប់ពី ..... ដល់ ..... តាមកិច្ចសន្យាចុះថ្ងៃ .....**" ជាទឹកពណ៌ខ្មៅ រួចបោះត្រាលេខាចារឹកពណ៌ក្រហម ។

- ក្នុងពេលជាមួយគ្នានេះ ត្រូវចុះបន្ទុកលើសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ និងប័ណ្ណដីរដ្ឋ ត្រង់ខ្ទង់បន្ទុកលើអចលនវត្ថុ សរសេរថា "**ផ្តល់សិទ្ធិសម្បទានដីសេដ្ឋកិច្ចរយៈពេល ... (...) ឆ្នាំ ជូន ..... តាមកិច្ចសន្យាចុះថ្ងៃ .....**" ឬ "**ជួលរយៈពេល ... ឆ្នាំ ឱ្យ ..... តាមកិច្ចសន្យាចុះថ្ងៃ .....** " ជាទឹកពណ៌ខ្មៅ រួចបោះត្រាលេខាចារឹកពណ៌ក្រហម ។

អាស្រ័យហេតុនេះ សូមលោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី ខេត្ត ជ្រាប និង ចាត់ចែងអនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាព ។

សូមលោកស្រី អស់លោក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

<u>ចម្លងជូន</u> :

- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
- សាលារាជធានី-ខេត្ត

" ដើម្បីជូនជ្រាប "

- ឯកសារ-កាលប្បវត្តិ